ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមក្នុង **«វេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទី២ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ»** និងកិច្ចប្រជុំសំខាន់ៗផ្សេងទៀត ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងប៉េកាំង ។

ឥស្សរជនអញ្ជើញអមដំណើរសម្តេចតេជោនាយករដ្ឋមន្ត្រី រួមមាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីពាណិជ្ជកម្ម ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីសុខាភិបាល ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីទេសចរណ៍ សមាជិកជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាផ្សេងទៀត និងថ្នាក់ដឹកនាំធុរកិច្ចនៃសភាពាណិជ្ជកម្មកម្ពុជា។

នៅក្នុងសម័យប្រជុំជាន់ខ្ពស់នៃវេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទី២ នៅថ្ងៃទី ២៦ ខែមេសា សម្តេចតេជោនាយករដ្ឋមន្ត្រីនឹងថ្លែងសុន្ទរកថាពីមូលបទរបស់វេទិកា **«កិច្ចសហប្រតិបត្តិការខ្សែក្រវ៉ាត់ និងផ្លូវៈ បង្កើតជោគវាសនារួមដ៏ត្រចះត្រចង់»**។ នៅថ្ងៃបន្ទាប់ នៅក្នុងសម័យប្រជុំតុមូលរបស់ថ្នាក់ដឹកនាំ សម្តេចតេជោនាយករដ្ឋមន្ត្រីនឹងអញ្ជើញចែករំលែកទស្សនវិស័យលើមូលបទ **«ការជម្រុញការតភ្ជាប់ ដើម្បីស្វែងរកធនធានថ្មីសម្រាប់ការរីកចម្រើន»**។

បន្ទាប់ពីអញ្ជើញចូលរួមវេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទី២ សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រមុខរដ្ឋ/រដ្ឋាភិបាលផ្សេងទៀត នឹងអញ្ជើញចូលរួមពិធីបើក**ពិព័រណ៍សាកវប្បកម្មអន្តរជាតិ២០១៩** ដែលនៅក្នុងឱកាសនោះ សម្តេចតេជោនាយករដ្ឋមន្ត្រីនឹងសម្ពោធពន្លាជាតិរបស់កម្ពុជា។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសចិន សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងមានជំនួបទ្វេភាគីដាច់ដោយឡែកពីគ្នា ជាមួយឯកឧត្តមប្រធានាធិបតី **ស៊ី ជីនពីង** ឯកឧត្តមនាយករដ្ឋមន្ត្រី **លី ខឺឈាង** ឯកឧត្តម **វ៉ាង ហ៊ុននីង** សមាជិកការិយាល័យនយោបាយ និងជាលេខានៃលេខាធិការដ្ឋាន

បក្សកុម្មុយនីស្តចិន។ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏នឹងជួបជាមួយ ឯកឧត្តម លី យ៉ុង អគ្គនាយក អង្គការឧស្សាហកម្មអង្គការសហប្រជាជាតិ ព្រមទាំងទទួលការចូលជួបសម្តែងការគួរសមពី តំណាងក្រុមហ៊ុនចិនមួយចំនួន។

ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ មានការរំពឹងថា នឹងមានការចុះហត្ថលេខា លើឯកសារមួយចំនួនស្តីពីជំនួយរបស់ចិន ព្រមទាំងគម្រោងកិច្ចសហប្រតិបត្តិការនានា ផងដែរ។

លើសពីនេះទៅទៀត សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងថ្លែងសុន្ទរកថាសំខាន់មួយ នៅក្នុង ពិធីជួបជាមួយនិស្សិត និងសាស្ត្រាចារ្យ នៅសកលវិទ្យាល័យប៉េកាំងក្នុងឱកាសដ៏ឧត្តុងឧត្តមដែល សម្តេចតេជោនាយករដ្ឋមន្ត្រីទទួលបាននូវការប្រគល់គោរមងារជាសាស្ត្រាចារ្យកិត្តិយសផ្នែកទំនាក់ **ទំនងអន្តរជាតិ ។**

ថ្ងៃចន្ទ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៩